ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងរដ្ឋប្បវេណីលេខៈ ២២៣ រប
ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០
សញ្ញាណរឿងក្តី៖ ប្តឹងសុំលែងលះប្តី
សាលក្រមលេខ៖ ០២៩ "ណ"
ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០

# នាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាល បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ។

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ក្រឡាបញ្ជី

## សាលាដំបូងខេត្តកណ្តាល

សាលាដំបូងខេត្តកណ្តាល បានចេញសាលក្រមដែលមានតួនាទីដូចខាងក្រោម:

**-ដើមចោទ:** ឈ្មោះ [redacted] បណ្តូល ភេទស្រី អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅ [redacted] ។

តំណាងដោយអាណត្តិ៖ លោក [redacted] ។

**-ចុងចម្លើយ:** ឈ្មោះ [redacted] ឧត្តមបញ្ញា ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើត [redacted] ។

តំណាងដោយអាណត្តិ៖គ្មាន។

**- កម្មវត្ថុ:** សុំលែងលះប្តីឈ្មោះ [redacted] ឧត្តមបញ្ញា

## អង្គហេតុ និងចំណុចវិវាទ

១. ការពន្យល់ត្រួសៗអំពីរឿងក្តី

ដើមចោទឈ្មោះ [redacted] បណ្តូល និងចុងចម្លើយឈ្មោះ [redacted] ឧត្តមបញ្ញា បានរៀបការតាមប្រពៃណីតាំងពីឆ្នាំ២០១៨ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ឡើយ ហើយការរួមរស់ជាមួយគ្នា ដើមចោទ និងចុងចម្លើយមានកូនចំនួន ០១ នាក់ ឈ្មោះ [redacted] បណ្ឌិត ភេទប្រុស អាយុ៨ (ប្រាំបី) ខែ ។ ហើយក្នុងអំឡុងពេលរួមរស់ជាមួយគ្នាដើមចោទ និងចុងចម្លើយមានទ្រព្យសម្បត្តិរួមដីទំហំ១៥ម៉ែត្រ គុណនឹង២០ម៉ែត្រ មានទីតាំងភូមិឃ្លាំងសម្បត្តិ ឃុំតស ស្រុកបាទី ខេត្តតាកែវ និងម៉ូតូម៉ាកសង់ស៊េរី-១៨ និងមានជំពាក់បំណុលរួម ដោយឪពុករបស់ដើមចោទជាអ្នកទិញ និងបានដាក់កាតគ្រី និងបានដាក់ឈ្មោះចុងចម្លើយ ។ ក្នុងការរស់នៅមិនចុះសម្រុងនឹងគ្នាចេះតែមានបញ្ហារការកូស មិនចេះចប់រហូតអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ទើបដើមចោទដាក់ពាក្យស្នើសុំបញ្ចាក់ឧត្តិភាពអាពាហ៍ពិពាហ៍រវាងខ្លួន និងចុងចម្លើយឈ្មោះ [redacted] ឧត្តមបញ្ញា តែម្តង ។



Scanned with CamScanner

២. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

មូលហេតុដែលដើមចោទប្តឹងសុំបញ្ចាក់នត្តិភាពនៃអាពាហ៍ពិពាហ៍ រវាងខ្លួន និងចុងចម្លើយឈ្មោះ [redacted] ឧត្តម បញ្ញា ដោយសារតែការរស់នៅមានភាពរកាំរកូស ខ្វែងគំនិតគ្នា និងមិនចុះសម្រុងនឹងគ្នា ជាហេតុធ្វើឱ្យខ្លួនរស់មនោសញ្ចេតនាមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ។

៣. សាលក្រមដែលទាមទារដោយដើមចោទ

- ប្តឹងសុំលែងលះប្តីឈ្មោះ [redacted] ឧត្តមបញ្ញា

៤. ការអះអាងរបស់ដើមចោទ

ដើមចោទឈ្មោះ [redacted] បណ្ឌូល បានអះអាងថា: នៅឆ្នាំ២០១៨ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] ឧត្តមបញ្ញា ។ ក្រោយមកចេះតែមានភាពរកាំរកូសជាមួយគ្នា ធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធជាមួយគ្នា ។ ខ្លួនសុំលែងលះពីប្តីឈ្មោះ [redacted] ឧត្តមបញ្ញា ដោយសុំសិទ្ធិគ្រប់គ្រងកូនប្រុសឈ្មោះ [redacted] បណ្ឌិត អាយុ០៨ (ប្រាំបី) ខែ និងសុំបែងចែកទ្រព្យសម្បត្តិរួមដីទំហំ ១៥ ម៉ែត្រ គុណនឹង ២០ ម៉ែត្រ ហើយសុំសងបំណុលរថយន្តមួយគ្រឿងម៉ាកព្រុស ស្លាកលេខ កណ្តាល ២B-៨០៧៤ ទៅឱ្យឪពុកម្តាយរបស់ខ្លួន ព្រមទាំងរាល់ការចំណាយបង់ពន្ធផ្សេងៗជាបន្ទុករបស់ចុងចម្លើយ ។ ហើយចំពោះម៉ូតូទ្រីមសង់ស៊េរីឆ្នាំ ២០១៩ ខ្លួនប្រគល់ឱ្យចុងចម្លើយគ្រប់គ្រង ។

៥. ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] ឧត្តមបញ្ញា បានអះអាងថា: ខ្លួនបានឯកភាពលើការទាមទារស្នើសុំលែងលះ ហើយខ្លួនសុំសិទ្ធិគ្រប់គ្រងលើកូនប្រុសឈ្មោះ [redacted] បណ្ឌិត អាយុ០៨ (ប្រាំបី) ខែ ។ ចំពោះការបែងចែកទ្រព្យសម្បត្តិដីទំហំ ១៥ ម៉ែត្រ គុណនឹង ២០ ម៉ែត្រ ខ្លួនទទួលស្គាល់ថាវាជាទ្រព្យសម្បត្តិរួម ។ ចំពោះរថយន្តមួយគ្រឿងម៉ាកព្រុស ស្លាកលេខ កណ្តាល ២B-៨០៧៤ ខ្លួនសុំប្រគល់ឱ្យទៅឪពុកក្មេក ។

៦. ទស្សុតាងជាឯកសាររួមមាន:

-ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍លេខ ២៥៦/១៨ មអពិ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ

-សំបុត្របញ្ជាក់កំណើតលេខ២៤ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២១០២១០០៨-១០១៥ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩

-បណ្ណសម្គាល់យានយន្តចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩ (មួយច្បាប់ថតចម្លង)

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ភាគីដើមចោទ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ភាគីចុងចម្លើយ

ក្រោយពីថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. ចំពោះការប្តឹងសុំលែងលះប្តី

–តុលាការអាចសម្រេចពីការលែងលះបាន ទាល់តែបុរសនារីដែលជាប្តីប្រពន្ធបានរស់នៅជាមួយគ្នាស្របច្បាប់ ពោលគឺបំពេញលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដែលមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី និងចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

–ក្រោយពីបានធ្វើការសាកសួរភាគីដើមចោទ ធ្វើការផ្សះផ្សា និងធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ តុលាការយល់ឃើញថា: គូភាគីពិតជាបានរួមរស់ជាមួយគ្នា ជាប្តីប្រពន្ធពិតប្រាកដមែន ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ដែលការរស់នៅជាមួយគ្នាមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នេះ គឺមិនមានអានុភាពគតិយុត្តជាប្តីប្រពន្ធស្របច្បាប់ឡើយ ។ គប្បីតុលាការចេញសាលក្រមសម្រេចច្រានចោលការទាមទាររបស់ដើមចោទ។



Scanned with CamScanner

-ទោះបីសាលាដំបូងចេញសាលក្រមសម្រេចច្រានចោលការទាមទាររបស់ដើមចោទក៏ដោយ មិនមែនមានន័យថាដើមចោទ និងចុងចម្លើយ មិនអាចទៅរៀបអាពាហ៍ពិពាហ៍ថ្មីនោះទេ គឺមានន័យថាដើមចោទ និងចុងចម្លើយអាចទៅរៀបអាពាហ៍ពិពាហ៍ថ្មីបាន ឱ្យតែបំពេញលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដែលមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី។

តុលាការយល់ឃើញថា ដើមចោទប្ដឹងសុំលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] ឧត្តមបញ្ញា គឺមាននត្ថិភាព គប្បីតុលាការច្រានចោលការទាមទាររបស់ដើមចោទ។

២. ចំពោះការទាមទារសិទ្ធគ្រប់គ្រងកូន

- តាមសំបុត្របញ្ជាក់កំណើតលេខ: ២០១៩ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] បណ្ឌិត អាចបញ្ជាក់បានថាឈ្មោះ [redacted] បណ្ឌិត ពិតជាកូនរបស់ដើមចោទ និងចុងចម្លើយប្រាកដមែន។

- ដើមចោទ និងចុងចម្លើយ ព្រមព្រៀងគ្នាប្រគល់សិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] បណ្ឌិត ភេទប្រុស កើតថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩ ទៅឱ្យដើមចោទជាអ្នកមានអំណាចមេបា។

តុលាការយល់ឃើញថា ដើមចោទទាមទារសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] បណ្ឌិត ភេទប្រុស កើតថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩ គឺមានអត្ថិភាព តុលាការនឹងពិចារណា និងសម្រេចតាមការទាមទារ។

៣. ចំពោះការទាមទារសិទ្ធិគ្រប់គ្រងដី

-តាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២១០២១០០៨-១០១៤ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ អាចបញ្ជាក់បានថា ដីមួយកន្លែងដែលមានទំហំ ៣០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិឃ្លាំងសម្បត្តិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ពិតជាកម្មសិទ្ធិរបស់ដើមចោទ និងចុងចម្លើយប្រាកដមែន ។ តុលាការយល់ឃើញថា សិទ្ធិគ្រប់គ្រងដីមួយកន្លែងដែលមានទំហំ ៣០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិឃ្លាំងសម្បត្តិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ និងមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២១០២១០០៨-១០១៤ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ ភាគីដើមចោទ និងចុងចម្លើយបានឯកភាពគ្នាចែកជាពីរចំណែកស្មើគ្នា ។ ដូច្នេះ តុលាការនឹងសម្រេចតាមការព្រមព្រៀងរបស់ភាគី។

-តាមបណ្ណសំគាល់យានយន្ត ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ អាចបញ្ជាក់បានថា រថយន្តមួយគ្រឿងម៉ាក TOYOTA PRIUS សេរីឆ្នាំ២០១៩ ពាក់ស្លាកលេខ កណ្ដាល 2B-8074 ពិតជាកម្មសិទ្ធិរបស់ចុងចម្លើយឈ្មោះ [redacted] ឧត្តមបញ្ញា ។ ដើមចោទ និងចុងចម្លើយ បានព្រមព្រៀងប្រគល់រថយន្តមួយគ្រឿងម៉ាក TOYOTA PRIUS សេរីឆ្នាំ២០១៩ ពាក់ស្លាកលេខ កណ្ដាល 2B-8074 ទៅឱ្យឪពុករបស់ដើមចោទ ព្រោះថារថយន្តមួយគ្រឿងនេះ ឪពុករបស់ដើមចោទជាអ្នកទិញឱ្យចុងចម្លើយ ។ គប្បីសាលាដំបូងសម្រេចតាមការព្រមព្រៀងរបស់ដើមចោទ និងចុងចម្លើយ។

៤-ប្រាក់ប្រដាប់ក្ដីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

## សេចក្ដីសម្រេចបញ្ចប់

១-ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ ស្រស់ បណ្ឌូល ត្រង់ចំណុចទី១ "ប្ដឹងសុំលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] ឧត្តមបញ្ញា"។

២-ឱ្យដើមចោទឈ្មោះ [redacted] បណ្ឌូល ភេទស្រី អាយុ ១៩ ឆ្នាំ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] បណ្ឌិត ភេទប្រុស កើតថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩ ។

៣- ទុកសិទ្ធិឱ្យចុងចម្លើយឈ្មោះ [redacted] ឧត្តមបញ្ញា មានសិទ្ធិសួរសុខទុក្ខកូនបាន រៀងរាល់ថ្ងៃសៅរ៍ និងអាទិត្យ រយៈពេល ០១ (មួយ) សប្ដាហ៍ម្ដង ចាប់ពីម៉ោង ០៦ ព្រឹក រហូតដល់ម៉ោង ០៥ ល្ងាច នៅកន្លែងស្នាក់នៅអចិន្ត្រៃយ៍របស់កូន ។ ចុងចម្លើយអាចយកកូនទៅលេងបានមួយយប់ ក្នុងមួយសប្ដាហ៍ ដោយពិភាក្សាជាមួយ



Scanned with CamScanner

អ្នកអាណាព្យាបាល និងកូន (ពេលកូនធំដឹងក្តី) ដោយមិនឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់កូន និងប្រគល់កូនឱ្យដល់អ្នកអាណាព្យាបាលវិញនៅទីតាំងកន្លែងស្នាក់នៅរបស់កូន ។

៤- ដីមួយកន្លែងដែលមានទំហំ ៣០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិឃ្លាំងសម្បត្តិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២១០២១០០៨-១០១៤ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ ត្រូវបែងចែកឱ្យដើមចោទ និងចុងចម្លើយជាពីរចំណែកស្មើគ្នា ។ រីឯ រថយន្តមួយគ្រឿងម៉ាក TOYOTA PRIUS ស៊េរីឆ្នាំ២០១៩ ពាក់ស្លាកលេខ កណ្តាល 2B-8074 ប្រគល់ឱ្យទៅឪពុករបស់ដើមចោទ ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះទាញហេតុផលផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ចំពោះមុខដើមចោទឈ្មោះ [redacted] បណ្ឌល និងចុងចម្លើយឈ្មោះ [redacted] ឧត្តមបញ្ញា ។

ទុកសិទ្ធិឱ្យគូភាគីប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃពុធ ៧រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្តាល, ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

"បានចម្លងត្រឹមត្រូវតាមសាលក្រមដើម"

កណ្តាល, ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រម**

[redacted]

[redacted]